បណ្ណព័ត៌មានអំពីជំងឺឆ្លង

# ជំងឺក្អកមាន់

*ជំងឺក្អកមាន់យាយីមនុស្សគ្រប់អាយុទាំងអស់ ប៉ុន្តែជំងឺនេះអាចមានភាពធ្ងន់ធ្ងរណាស់ចំពោះទារក។ ការចាក់ថ្នាំបង្ការរោគនៅអាយុពីរខែ បួនខែ និងប្រាំមួយខែ អាចបង្ការជំងឺនេះបាន។ ការចាក់ថ្នាំបន្ថែមគឺជាការចាំបាច់សំរាប់កុមារអាយុបួនឆ្នាំនិងក្មេងជំទង់ ព្រមទាំងមនុស្សពេញវ័យដែលរស់នៅឬធ្វើការជាមួយកុមារតូចៗ។*

## តើក្អកមាន់គឺជាជំងឺអ្វី?

ក្អកមាន់គឺជាជំងឺមួយបណ្តាលដោយការឆ្លងបាក់តេរី *Bordetella pertussis* ទៅក្នុងបំពង់ក។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

- ជាធម្មតា ជំងឺក្អកមាន់ចាប់ផ្តើមដូចជាកើតផ្តាសាយយ៉ាងដូច្នោះដែរ ដោយមានការហៀរសំបោរ  អស់កម្លាំង និងជួនកាលគ្រុនក្តៅមិនសូវខ្លាំងឡើយ។
- បន្ទាប់មកអ្នកជំងឺកើតមានក្អក ជាធម្មតាមានពេលក្អកជាប់គ្នា និងមានការដង្ហក់រកខ្យល់ជាខ្លាំងមួយនៅគ្រាក្រោយពីនោះ។ ជួនកាលទៅអ្នកខ្លះអាចក្អួតនៅក្រោយពីក្អកហើយ។
- ជំងឺក្អកមាន់អាចមានភាពធ្ងន់ធ្ងរណាស់ចំពោះកុមារតូចៗ។ កុមារទាំងនេះប្រហែលជាមានមុខឡើងស្លេកស្លាំង ឬឈប់ដកដង្ហើមក្នុងអំឡុងពេលក្អកខ្លាំង ហើយអាចត្រូវធ្វើដំណើរទៅមន្ទីរពេទ្យ។
- កុមារធំៗនិងមនុស្សពេញវ័យអាចមានជំងឺមិនសូវធ្ងន់ធ្ងរដូចកុមារតូចៗឡើយ។ អ្នកទាំងនេះមានគ្រាក្អកជាប់គ្នាដែលបន្តពេលជាច្រើនអាទិត្យ ទោះជាមានការព្យាបាលក៏ដោយ។

## តើជំងឺនេះឆ្លងតាមរបៀបណា?

ជំងឺក្អកមាន់ឆ្លងទៅកាន់អ្នកដទៃតាមរយៈចំហាយទឹកមាត់ដែលក្អកចេញ ឬចំហាយសំបោរចេញពីការកណ្តាស់។ បើមិនព្យាបាលទេ អ្នកកើតជំងឺក្អកមាន់អាចចម្លងមេរោគនេះទៅកាន់អ្នកដទៃរយៈពេលរហូតដល់ទៅបីអាទិត្យ ក្រោយពីក្អកបានកើតមានឡើង។

ជាធម្មតា រយៈពេលចាប់ពីពេលប៉ះពាល់មេរោគរហូតដល់ពេលកើតជំងឺគឺប្រាំពីរទៅដប់ថ្ងៃ  ប៉ុន្តែអាចមានរយៈពេលដល់ទៅបីអាទិត្យទៀតផង។

## តើអ្នកណាខ្លះដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

- ជនរាល់រូបអាចកើតជំងឺក្អកមាន់។
- អ្នកដែលរស់នៅក្នុងផ្ទះជាមួយនឹងអ្នកកើតជំងឺក្អកមាន់ ទំនងជាឆ្លងជំងឺនេះ។
- ការចាក់ថ្នាំបង្ការរោគកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជំងឺនេះ  ប៉ុន្តែការកើតមានជំងឺនេះសាជាថ្មីអាចកើតមានឡើង។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

### ឲ្យកូនលោកចាក់ថ្នាំបង្ការរោគទាន់ពេល

- ថ្នាំបង្ការរោគមិនផ្តល់ការការពារមួយជីវិតទល់នឹងជំងឺក្អកមាន់ទេ ហើយជួនកាលការការពារក៏មិនបានពេញលេញដែរ។
- កុមារត្រូវចាក់ថ្នាំនៅពេលមានអាយុពីរខែ បួនខែ និងប្រាំមួយខែ។
- ការចាក់ថ្នាំបន្ថែមគឺជាការចាំបាច់នៅពេលកុមារមានអាយុបួនឆ្នាំ និងម្តងទៀតនៅពេលមានអាយុ 15 ឆ្នាំ។
- វេជ្ជបណ្ឌិតព្យាបាលជំងឺទូទៅនិងសាលាក្រុងខ្លះផ្តល់ការចាក់ថ្នាំបង្ការរោគនេះ។

### កុំឲ្យទារកលោកអ្នកទៅជិតអ្នកដែលក្អក

- ទារកត្រូវការថ្នាំបង្ការរោគពីរឬបីលើកមុនពេលទារកទាំងនោះអាចការពារទល់នឹងជំងឺក្អកមាន់បាន។ ដោយសារមូលហេតុនេះហើយ ជាការសំខាន់ក្នុងការកុំឲ្យអ្នកមានជំងឺក្អកទៅជិតទារកលោកអ្នកឡើយ ដើម្បីកុំឲ្យអ្នកទាំងនោះចម្លងជំងឺក្អកមាន់ឬមេរោគផ្សេងទៀតទៅកាន់ទារកលោកអ្នក។

### ចាក់ថ្នាំបង្ការរោគ បើលោកអ្នកគឺជាជនពេញវ័យដែលមានការប៉ះពាល់ជិតស្និទ្ធនឹងកុមារតូចៗ

មានថ្នាំបង្ការរោគសំរាប់មនុស្សពេញវ័យ។ ថ្នាំនេះគួរចាក់ឲ្យ៖

- ទាំងមាតានិងទាំងបិតានៅពេលគ្រោងមានផ្ទៃពោះ ឬក្រោយពេលទារកប្រសូតហើយភ្លាម
- ជនពេញវ័យដែលធ្វើការជាមួយកុមារក្មេងៗ ជាពិសេសនៅក្នុងមណ្ឌលថែទាំកុមារ បុគ្គលិកថែទាំសុខភាព និងបុគ្គលិកថែទាំកុមារ។

### បើលោកអ្នកប៉ះពាល់ជិតស្និទ្ធជាមួយអ្នកកើតជំងឺក្អកមាន់៖

- សូមប្រុងប្រយ័ត្នអំពីរោគសញ្ញាទាំងឡាយ។ បើកើតមានរោគសញ្ញា សូមទៅជួបវេជ្ជបណ្ឌិតលោកអ្នក យកប័ណ្ណព័ត៌មាននេះទៅជាមួយលោកអ្នក ហើយប្រាប់វេជ្ជបណ្ឌិតថាលោកអ្នកបានប៉ះពាល់អ្នកកើតជំងឺក្អកមាន់។
- អ្នកប៉ះពាល់ជិតស្និទ្ធខ្លះដែលមានគ្រោះថ្នាក់ខ្លាំង(ឧទាហរណ៍៖ កុមារអាយុតិចជាងមួយឆ្នាំ កុមារមិនបានចាក់ថ្នាំបង្ការរោគពេញលេញ និងស្ត្រីមានផ្ទៃពោះជិតគ្រប់ខែ) និងអ្នកដទៃទៀតដែលរស់នៅឬធ្វើការជាមួយអ្នកមានគ្រោះថ្នាក់ខ្លាំងអាចត្រូវប្រើថ្នាំអង់ទីប៊ីយោទិកដើម្បីបង្ការជំងឺនេះ។

### បើលោកអ្នកកើតជំងឺក្អកមាន់៖

- សូមទទួលការព្យាបាលឲ្យទាន់ពេលនៅក្នុងពេលកើតជំងឺនេះ ចៀសវាងអ្នកដទៃនិងកុំទៅជិតកុមារក្មេងៗ ឧទាហរណ៍៖ នៅតាមមណ្ឌលថែទាំកុមារ មត្តេយ្យសាលា និងសាលារៀន។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

បើវេជ្ជបណ្ឌិតយល់ថា អ្នកណាមួយកើតជំងឺក្អកមាន់ វេជ្ជបណ្ឌិតនោះនឹងធ្វើតេស្តសំណាកសារធាតុពីទីជំរៅនៃរន្ធប្រមុះ ឬធ្វើតេស្តឈាម ដើម្បីជួយបញ្ជាក់ថាតើអ្នកនោះកើតជំងឺនេះដែរឬទេ។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

ថ្នាំអង់ទីប៊ីយោទិកពិសេស – ជាធម្មតាគឺប្រើថ្នាំ azithromycin, erythromycin ឬ clarithromycin ដើម្បីព្យាបាលជំងឺក្អកមាន់។ ថ្នាំអង់ទីប៊ីយោទិកទាំងនេះអាចបង្ការការឆ្លងរាលដាលមេរោគទៅកាន់អ្នកដទៃ។

ជាញឹកញយ ការក្អកកើតមានជាច្រើនអាទិត្យតទៅទៀត ទោះជាមានការព្យាបាលហើយក៏ដោយ។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

វេជ្ជបណ្ឌិតនិងមន្ទីរពិសោធន៍ត្រូវរាយការណ៍ដោយលាក់ការសម្ងាត់នូវករណីនៃជំងឺក្អកមាន់ទៅកាន់ផ្នែកសុខភាពសាធារណៈ (Public Health Unit) ក្នុងតំបន់។ បុគ្គលិកផ្នែកសុខភាពសាធារណៈអាចផ្តល់ឱវាទអំពីវិធីប្រសើរបំផុតក្នុងការបញ្ឈប់ការឆ្លងរាលដាលតទៅទៀត។

កុមារដែលកើតជំងឺនេះ មិនត្រូវទៅមត្តេយ្យសាលានិងសាលារៀនឡើយ។ អ្នកប៉ះពាល់មេរោគដែលគ្មានចាក់ថ្នាំបង្ការរោគនេះ អាចទទួលការហាមឃាត់មិនឲ្យទៅមណ្ឌលថែទាំកុមារ លុះត្រាតែអ្នកទាំងនោះប្រើថ្នាំអង់ទីប៊ីយោទិកពិសេស។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**